# សមាគមខ្មែរសាជីវកម្ម រដ្ឋអូស្ត្រាលីខាងត្បូង
**Cambodian Association of South Australia Inc.**
63 Commercial Road, Salisbury SA 5108 Mobile: 0416 762 524
Email: info@cambodianassociationsa.org.au


## សេចក្តីប្រកាសព័ត៌មាន

**សមាគមខ្មែរសាជីវកម្មរដ្ឋអូស្ត្រាលីខាងត្បូង** សូមប្រកាស និងប្រគេន ព្រមទាំងជូនដំណឹងដល់ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ និងប្រជាពលរដ្ឋខ្មែរដែលរស់នៅរដ្ឋអូស្ត្រាលីខាងត្បូងឱ្យបានជ្រាបថា បន្ទាប់ពីការខំប្រឹងខ្នះខ្នែងជាច្រើនខែកន្លងមកនេះ សមាគមខ្មែរយើងមានលទ្ធភាពនឹងអាចជួលបុគ្គលិកពីររូប ដើម្បីនឹងបម្រើសេវាកម្មឱ្យបានជាប់លាប់ ជូនដល់ បងប្អូន ប្រជាពលរដ្ឋខ្មែរយើងដែលត្រូវការ។

សេវាកម្មដែលបុគ្គលិកសមាគមខ្មែរយើងនឹងមានបម្រើជូន មានរៀបរាប់ដូចខាងក្រោមនេះ ៖

- ✓ ជួយណែនាំ និងបញ្ជូនទៅអ្នកមានជំនាញការ ដើម្បីផ្តល់ឱវាទផ្នែកគ្រប់គ្រងហិរញ្ញវត្ថុ និងថវិកាផ្ទាល់ខ្លួន
- ✓ ជួយពិនិត្យ បំពេញ និងផ្តល់យោបល់លើលិខិតស្នាម និងរបាយការណ៍នានា
- ✓ សេវាកម្ម JP (Justice of the Peace) ជាភាសាខ្មែរ
- ✓ ជួយសម្រួល និងជួយទាក់ទងទៅអង្គការនានា ដែលមានលទ្ធភាពអាចជួយប្រជាពលរដ្ឋខ្មែរដែល ៖
  - មានវិបត្តិផ្លូវចិត្ត
  - មានបញ្ហាក្នុងក្រុមគ្រួសារ (អំពើហិង្សា ការរំលោភអំណាចបុគ្គលភាព...)
  - មានបញ្ហាគ្រឿងញៀន និងបញ្ហាល្បែងស៊ីសង
  - ទើបតែមករស់នៅរដ្ឋអូស្ត្រាលីខាងត្បូង
- ✓ អប់រំផ្សព្វផ្សាយអំពី ៖
  - វិធីបង្ការជំងឺ និងសេវាកម្មសុខុមាលភាព សុខាភិបាល និងសុខភាពសាធារណៈ
  - សិទ្ធិ និងសេរីភាពសាធារណៈ ទាក់ទងនឹងច្បាប់ និងបញ្ហាពលកម្មការងារ។

បុគ្គលិកសមាគមខ្មែរយើងនឹងធ្វើការសម្របសម្រួលព្រមទាំងបង្កលក្ខណៈងាយស្រួលដោយផ្តល់សេវាកម្មដល់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដោយមិនប្រកាន់និន្នាការជំនឿសាសនា / ទីកន្លែងធ្វើសក្ការៈបូជា ឬ ជំនឿនយោបាយណាមួយឡើយ។ បុគ្គលិកយើងប្រកាន់នូវភាពអព្យាក្រឹត សុចរិតទៀងត្រង់ហើយរាល់ **សេវាកម្មទាំងអស់មិនត្រូវបានគិតតម្លៃអ្វីឡើយ និងត្រូវរក្សាជាការសម្ងាត់**។

ចំពោះព័ត៌មានបន្ថែម ឬ ដើម្បីណាត់ជួប សូមទាក់ទងមក បុគ្គលិកសង្គមកិច្ចសម្រាប់សហគមន៍ខ្មែរ ៖

លោក **វី វឌ្ឍនៈ** (Wathnak Vy)
ថ្ងៃធ្វើការ ថ្ងៃចន្ទ និងថ្ងៃអង្គារ
វេលាម៉ោង ៩ ព្រឹក ដល់ម៉ោង 5 រសៀល
(Monday & Tuesday 9am to 5pm)
អ៊ីម៉ែល wathnak.vy@cambodianassociationsa.org.au

អ្នកស្រី **ម៉ាន់ ឆារីដា** (Chharida Mann)
ថ្ងៃពុធ និងថ្ងៃព្រហស្បតិ៍ វេលាម៉ោង ៩ ព្រឹក ដល់ម៉ោង 4 រសៀល
ថ្ងៃសុក្រ វេលាម៉ោង ៩ ព្រឹក ដល់ម៉ោង 11 ព្រឹក
(Wednesday & Thursday 9am to 4pm)
(Friday 9am – 11am)
អ៊ីម៉ែល chharida.cambodianassociationsa@gmail.com

លេខទូរស័ព្ទ **0416 762 524**

អាសយដ្ឋាន *Life Without Barriers* 63 Commercial Road, SALISBURY SA 5108

គេហទំព័រ www.cambodianassociationsa.org.au


*តួនាទី បុគ្គលិកសង្គមកិច្ចសម្រាប់សហគមន៍ខ្មែរ ទទួលបានមូលនិធិពីក្រសួងសេវាកម្មធនធានមនុស្ស តាងនាមឱ្យរាជរដ្ឋាភិបាលរដ្ឋអូស្ត្រាលីខាងត្បូង*

*Cambodian Community Welfare Worker roles funded by the Department of Human Services on behalf of the Government of South Australia.*